Washington State Department of Early Learning

Early Support for Infants and Toddlers

# ច្បាប់អប់រំបុគ្គលដែលមានពិការភាព (IDEA) ស្តីពី នីតិវិធីការពារក្រោមមាត្រា Part C (សិទ្ធិមាតាបិតា)

DEL 11-001a CA (Rev. 7/12)

## បុព្វកថា

**ច្បាប់អប់រំបុគ្គលដែលមានពិការភាព** (Individuals with Disabilities Education Act, IDEA) គឺជាច្បាប់សហព័ន្ធ ដែលមានបទបញ្ញត្តិគ្រប់គ្រងសេវាអន្តរាគមនបឋមវ័យ សម្រាប់ទារក និងកូនក្មេងតូចៗ (អាយុចាប់ពីថ្ងៃកើតរហូតដល់ 36 ខែ) ដែលមានពិការភាព និងគ្រួសាររបស់ពួកគេ។ បទបញ្ញត្តិគ្រប់គ្រងទាំងនេះមានចែងក្រោមមាត្រា Part C នៃច្បាប់ IDEA ដែលពិពណ៌នាអំពីបទបញ្ញាសហព័ន្ធ (34 CFR Part 303) ហើយ និងច្បាប់គ្រប់គ្រង និងនីតិវិធីនានារបស់រដ្ឋវ៉ាស៊ីនតោន។

នៅក្នុងរដ្ឋវ៉ាស៊ីនតោន, ប្រព័ន្ធ Part C មានឈ្មោះថា **កម្មវិធីឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកូនក្មេងអាយុពីរបីឆ្នាំ** (Early Support for Infants and Toddlers, ESIT)។ ប្រព័ន្ធនេះបានត្រូវបង្កើតឡើង ដើម្បីជម្រុញឲ្យមានការចូលរួមពីក្រុមគ្រួសារឲ្យបានជាអតិបរិមា ព្រមទាំងធានា ឲ្យមានការយល់ព្រមពីឪពុកម្តាយនៅក្នុងជំហានទីមួយៗនៃដំណើរការអន្តរាគមន៍បឋមវ័យនេះ ដោយចាប់ផ្តើមពីការបញ្ជូនជាលើកដំបូង ហើយបន្តរហូតដល់ការចែកចាយសេវាកម្ម និងអន្តរកាល។

កម្មវិធី ESIT រួមមាននូវនីតិវិធីការពារ ដើម្បីការពារសិទ្ធិមាតាបិតា និងកូន។ ឪពុកម្តាយត្រូវតែបានទទួលព័ត៌មានស្តីអំពីនីតិវិធីការពារទាំងនេះ តាមសេចក្តីចែងក្រោមបទបញ្ញាសហព័ន្ធ នៅ 34 CFR 303.400-438, ដែលរួមមាននូវជម្រើសនៃការដោះស្រាយវិវាទ នៅ 34 CFR 303.430-438, ដើម្បីឲ្យពួកគេអាចចូលរួមដោយសកម្ម ហើយមានតួនាទីដឹកនាំក្នុងសេវាកម្មទាំងឡាយ ដែលបានផ្តល់ដល់កូន និងគ្រួសាររបស់ពួកគេ។ ឯកសារស្តីពីសិទ្ធិមាតាបិតានេះគឺជាសេចក្តីជូនដំណឹងផ្លូវការស្តីអំពីនីតិវិធីការពារកូន និងគ្រួសារ ដែលបានចែងក្រោមបទបញ្ញានៃមាត្រា Part C របស់សហព័ន្ធ។

បន្ថែមពីនេះ ព័ត៌មានស្តីអំពីនីតិវិធីការពារកូន និងគ្រួសារ មានបម្រុងជូនទៅតាមការិយាល័យរបស់អ្នកសម្របសម្រួលធនធានគ្រួសារ (Family Resources Coordinator, FRC) និងការិយាល័យរបស់អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ (Early Intervention Service Provider) ក្រោមវិធានការសេវាអន្តរាគមន៍បឋមវ័យ។

> ***អ្នកសម្របសម្រួលធនធានគ្រួសារ (FRC),*** *ធ្វើការជាមួយគ្រួសារលោកអ្នក, អាចជួយផ្តល់យោបល់ណែនាំជូនលោកអ្នក អំពីសម្ភារៈបរិក្ខារបន្ថែមផ្សេងៗ ដើម្បីជួយគ្រួសារលោកអ្នក ឲ្យបានយល់អំពីនីតិវិធីការពារក្រោមមាត្រា Part C។ អ្នកសម្របសម្រួលអាចជួយផ្តល់យោបល់ណែនាំជូនលោកអ្នកផងដែរ អំពីមធ្យោបាយផ្សេងៗ ដែលលោកអ្នក និងសមាជិកនៃគ្រួសារដទៃៗទៀត អាចរួមធ្វើជាដៃគូជួយគ្នាទៅវិញទៅមក ដើម្បីបំពេញតម្រូវការផ្នែកអភិវឌ្ឍន៍ទីតិ និងកាយសម្បទារបស់កូនលោកអ្នក។*

## សេចក្តីសង្ខេបអំពីនីតិវិធីការពារ (សិទ្ធិមាតាបិតា)

នៅក្នុង**កម្មវិធីឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកូនក្មេងអាយុពីរបីឆ្នាំ,** លោកអ្នក ដែលជាឪពុកម្តាយ មានសិទ្ធិដូចតទៅ ៖

- សិទ្ធិទទួលបានការវាយតម្លៃមើលលទ្ធផល្ត និងការវាយតម្លៃមើលវិធិសាស្ត្រ ដោយរួមមានទាំងការអភិវឌ្ឍន៍ **ផែនការសេវាសម្រួលតាមសេចក្តីត្រូវការពិសេសរបស់គ្រួសារទីមួយៗ** (Individualized Family Service Plan (IFSP)) នៅក្នុងកិច្ចប្រជុំ IFSP លើកដំបូង, ក្នុងរយៈពេល 45 ថ្ងៃប្រតិទិ រាប់ចាប់ពីថ្ងៃបញ្ជូន។

> ***"សេវាអន្តរាគមន៍បឋមវ័យសមស្រប" ("appropriate early intervention services")*** *ត្រូវបានកំណត់តាមរយៈផែនការ IFSP ។ IFSP ត្រូវតែរួមបញ្ចូលសេចក្តីថ្លែងការណ៍ស្តីពីសេវាអន្តរាគមន៍បឋមវ័យជាក់លាក់ ដែលចាំបាច់ដើម្បីបំពេញតម្រូវការពិសេសរបស់សាមីកុមារ និងគ្រួសាររបស់គេ ដើម្បីសម្រេចបានលទ្ធផល ដែលបានកំណត់ក្នុងផែនការ IFSP។ Federal បទបញ្ញា Part C របស់សហព័ន្ធ [http://www.gpo.gov/fdsys/pkg/FR-2011-09-28/pdf/2011-22783.pdf](http://www.gpo.gov/fdsys/pkg/FR-2011-09-28/pdf/2011-22783.pdf) បានឲ្យនិយមន័យលើពាក្យ សេវាអន្តរាគមន៍បឋមវ័យ ថាជាសេវាដែល "ត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការលើផ្នែកអភិវឌ្ឍន៍ទីតិ និងកាយសម្បទារបស់កុមារដែលមានលក្ខណសម្បត្តិទទួលជំនួយក្រោមមាត្រា Part C និងតម្រូវការរបស់គ្រួសារពាក់ព័ន្ធ ដើម្បីជួយជម្រុញការអភិវឌ្ឍន៍ទីតិ និងកាយសម្បទារបស់សាមីកុមា។"*

- សិទ្ធិទទួលបានការវាយតម្លៃមើលលទ្ធផល, ការវាយតម្លៃមើលវិធីសាស្ត្រ, ការអភិវឌ្ឍន៍ផែនការ IFSP, សេវាសម្របសម្រួល, និងនីតិវិធីការពារសិទ្ធិ ដោយឥតគិតថ្លៃ។
- សិទ្ធិទទួលបានការវាយតម្លៃមើលលទ្ធផល, ប្រសិនបើលោកអ្នកស្នើសុំ និងផ្តល់ការយល់ព្រមសម្រាប់វា, នៅពេលណាក៏បានក្នុងអំឡុងពេលពិនិត្យ (ប្រសិនបើប្រើ)។
- ប្រសិនបើមានលក្ខណសម្បត្តិក្រោមមាត្រា Part C, នោះសិទ្ធិទទួលបាន**សេវាអន្តរាគមន៍បឋមវ័យសម្រួលតាមសេចក្តីត្រូវការពិសេស**របស់កូន និងគ្រួសារលោកអ្នក ទៅតាមសេចក្តីចែងក្នុងផ្នែកការ IFSP។
- សិទ្ធិមិនទទួលការពិនិត្យ, ការវាយតម្លៃមើលលទ្ធផល, ការវាយតម្លៃមើលវិធីសាស្ត្រ, និងសេវាកម្មផ្សេងៗ។
- សិទ្ធិទទួលបានការអញ្ជើញ និងចូលរួមក្នុងកិច្ចប្រជុំទាំងអស់ ដើម្បីធ្វើសេចក្តីសម្រេចផ្សេងៗ ដែលពាក់ព័ន្ធការស្នើសុំផ្លាស់ប្តូរអត្តសញ្ញាណ, ការវាយតម្លៃមើលលទ្ធផល, ការដាក់កូនរបស់លោកអ្នកឲ្យគេជួយចិញ្ចឹម, ឬវិធានការសេវាអន្តរាគមន៍បឋមវ័យសម្រាប់កូន និងគ្រួសាររបស់លោកអ្នក។
- សិទ្ធិទទួលបានសេចក្តីជូនជាលាយលក្ខណ៍អក្សរទាន់ពេលវេលា មុនពេលការផ្លាស់ប្តូរអត្តសញ្ញាណ, ការវាយតម្លៃមើលលទ្ធផល, ឬការដាក់កូនរបស់លោកអ្នកឲ្យគេជួយចិញ្ចឹម, ឬវិធានការសម្របសម្រួលសេវាអន្តរាគមន៍បឋមវ័យសម្រាប់កូន និងគ្រួសាររបស់លោកអ្នកត្រូវបានគេស្នើឡើង ឬត្រូវបានគេបដិសេធ។
- សិទ្ធិទទួលបានសេវាអន្តរាគមន៍បឋមវ័យនីមួយៗ ទៅតាមវិសាលភាពនៃបរិបទធម្មជាតិ ដែលសមស្របតាមសេចក្តីត្រូវការពិសេសខាងផ្នែកអភិវឌ្ឍន៍ទីតិ និងកាយសម្បទារបស់កូនលោកអ្នក។
- សិទ្ធិទទួលបានកិច្ចការពារភាពលាក់ការសម្ងាត់ចំពោះ**ព័ត៌មានពាក់ព័ន្ធអត្តសញ្ញាណសម្គាល់ខ្លួន**ជានិច្ច។
- សិទ្ធិទទួលបានសំណៅចម្លងដំបូងនៃឯកសារស្តីពីសេវាអន្តរាគមន៍បឋមវ័យរបស់កូនលោកអ្នក ដោយឥតគិតថ្លៃ។
- សិទ្ធិទទួលបានសំណៅចម្លងនៃលិខិតវាយតម្លៃមើលលិទ្ធផល, លិខិតវាយតម្លៃមើលវិធីសាស្ត្រ, និងផែនការ IFSP ដែលគេត្រូវតែប្រគល់ជូនលោកអ្នកឲ្យបានឆាប់តាមដែលអាចធ្វើ បន្ទាប់ពីកិច្ចប្រជុំ IFSP នីមួយៗ។
- សិទ្ធិត្រួតពិនិត្យមើលឡើងវិញ ហើយបើចាំបាច់ កែតម្រូវឯកសាររបស់កូនលោកអ្នក។
- សិទ្ធិស្នើសុំការសម្រុះសម្រួល និង/ឬសវនាការត្រឹមត្រូវតាមច្បាប់ដោយឥតលំអៀង ដើម្បីដោះស្រាយទំនាស់រវាងឪពុកម្តាយ/អ្នកផ្តល់សេវា។
- សិទ្ធិដាក់បណ្តឹងរដ្ឋបាល។

បន្ថែមលើសិទ្ធិទាំងឡាយដែលបានបញ្ជាក់ជូនខាងលើ, លោកអ្នកនៅមានសិទ្ធិទទួលបានសេចក្តីជូនដំណឹងលាយលក្ខណ៍អក្សរ ស្តីពីនីតិវិធីការពារជាក់លាក់ ដែលមានចែងក្រោមមាត្រា Part C។ សិទ្ធិទាំងនេះត្រូវបានពិពណ៌នាជូននៅខាងក្រោម។

> ***ព័ត៌មានពាក់ព័ន្ធអត្តសញ្ញាណសម្គាល់ខ្លួន (personally identifiable information)*** *គឺរួមមាន ៖ 1) ឈ្មោះរបស់កូនលោកអ្នក, ឈ្មោះរបស់លោកអ្នក, ឬឈ្មោះរបស់សមាជិកដទៃទៀតក្នុងគ្រួសារលោកអ្នក; 2) អាសយដ្ឋានរបស់កូន ឬគ្រួសារលោកអ្នក; 3) កត្តាសម្គាល់ខ្លួនផ្ទាល់ ដូចជាលេខសូសាល់របស់កូន ឬរបស់លោកអ្នក; 4) កត្តាសម្គាល់ខ្លួនប្រយោលផ្សេងៗទៀត ដូចជាខែថ្ងៃឆ្នាំកំណើត, ទីកន្លែងកើត, និងឈ្មោះម្តាយពីក្រមុំរបស់កូនលោកអ្នក; 5) អត្តចរិត ឬព័ត៌មានដទៃៗទៀត ដែលអាចនឹងនាំឲ្យគេស្គាល់អត្តសញ្ញាណរបស់កូនលោកអ្នកដោយកម្រិតណាមួយ; ឬ 6) ព័ត៌មានដែលស្នើសុំដោយមនុស្សណាម្នាក់ដែលទីភ្នាក់ងារនៃកម្មវិធីអន្តរាគមន៍បឋមវ័យមានមូលហេតុជឿថា ស្គាល់កូនរបស់លោកអ្នក។*

## សេចក្តីជូនដំណឹងលាយលក្ខណ៍អក្សរជាមុន

សេចក្តីជូនដំណឹងលាយលក្ខណ៍អក្សរជាមុនត្រូវតែបានប្រគល់ជូនលោកអ្នកនៅក្នុងរយៈពេលដ៏សមរម្យណាមយ មុនពេលអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យស្នើសុំ ឬបដិសេធ មិនចាប់ផ្តើម ឬផ្លាស់ប្តូរអត្តសញ្ញាណ, ការវាយតម្លៃមើលលទ្ធផល, ឬការដាក់កូនឲ្យគេជួយចិញ្ចឹម, ឬវិធានការសេវាអន្តរាគមន៍បឋមវ័យសមរម្យណាមួយ ជូនកូន និងគ្រួសាររបស់លោកអ្នក។ សេចក្តីជូនដំណឹងត្រូវតែជម្រាបព័ត៌មានពិស្តារជូនលោកអ្នកស្តីអំពី ៖

- វិធានការ ដែលកំពុងតែត្រូវបានស្នើ ឬបដិសេធដោយអ្នកមានកិច្ចសន្យាផ្តល់សេវាអន្តរាគមន៍បឋមវ័យ ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ។
- មូលហេតុសម្រាប់អនុវត្តន៍វិធានការ។
- នីតិវិធីការពារទាំងអស់ ដែលមានបម្រុងជូនក្រោមមាត្រា Part C។
- នីតិវិធីផ្សះផ្សារបស់រដ្ឋ, បណ្តឹងរបស់រដ្ឋ, និងនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់, ដោយរួមមានទាំងបទពណ៌នាអំពីរបៀបដាក់ពាក្យបណ្តឹង និងកាលវិភាគសម្រាប់នីតិវិធីទាំងនោះ។

សេចក្តីជូនដំណឹងនេះត្រូវតែបានសរសេរឡើងក្នុងភាសា ដែលសាធារណៈជន ហើយផ្តល់ជូនលោកអ្នកក្នុងភាសាកំណើតរបស់លោកអ្នក, លើកលែងតែមានមូលហេតុច្បាស់លាស់បង្ហាញថាគ្មានមធ្យោបាយណាអាចធ្វើដូច្នោះបាន។

ប្រសិនបើភាសាកំណើត ឬបែបបទនិយាយទាក់ទងតាមមធ្យោបាយផ្សេងៗទៀតរបស់លោកអ្នក មិនមែនជាភាសា ដែលមានអក្សរសាស្ត្រអាចសរសេរបាន, នោះអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យគប្បីអនុវត្តវិធានការណាមួយ ដើម្បីធានាថា ៖

- សេចក្តីជូនដំណឹងត្រូវបានបកប្រែដោយមាត់ ឬដោយមធ្យោបាយដទៃទៀត ជូនលោកអ្នកក្នុងភាសាកំណើត ឬក្នុងបែបបទនិយាយទាក់ទងតាមមធ្យោបាយផ្សេងៗទៀតរបស់លោកអ្នក;
- លោកអ្នកយល់សេចក្តីជូនដំណឹងនេះ; ហើយ
- មានភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថាលក្ខខណ្ឌតម្រូវនានា ដែលបានពណ៌នាក្នុងនីតិវិធីទាំងនេះត្រូវបានបំពេញស្រេចបាច់។

## សេចក្តីយល់ព្រមរបស់មាតាបិតា

សេចក្តីយល់ព្រមមានន័យថា ៖

- លោកអ្នកត្រូវបានគេជម្រាប់ប្រាប់ព័ត៌មានសព្វគ្រប់ដែលទាក់ទងនឹងសកម្មភាព ដែលគេកំពុងស្វែងរកការយល់ព្រមក្នុងភាសារបស់លោកអ្នក;
- លោកអ្នកជ្រាប ហើយយល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីអនុវត្តសកម្មភាព ដែលនាំឲ្យលោកអ្នកត្រូវផ្តល់សេចក្តីយល់ព្រមនេះ ហើយសេចក្តីយល់ព្រមរបស់លោកអ្នកត្រូវពណ៌នាអំពីសកម្មភាព និងបញ្ជីឯកសារសេវាអន្តរាគមន៍បឋមវ័យនានា (បើមាន) ដែលនឹងត្រូវគេបញ្ចេញ និងឈ្មោះជនដែលគេត្រូវបញ្ចេញឲ្យ;
- លោកអ្នកជ្រាបថា ការផ្តល់សេចក្តីយល់ព្រមនេះគឺត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយលោកអ្នកអាចដកយកវិញនៅពេលណាក៏បាន។

បើលោកអ្នកដកយកសេចក្តីយល់ព្រមរបស់លោកអ្នកវិញ, នោះសកម្មភាពពាក់ព័ន្ធទាំងប៉ុន្មាន ដែលគេបានអនុវត្តកន្លងទៅ ត្រូវចាត់ទុកជាមោឃៈ (មានន័យថា លោកអ្នកមិនអាចដកយកទាំងអ្វី ដែលបានកើតឡើងកន្លងហួសទៅហើយនោះផងដែរទេ)។

សេចក្តីយល់ព្រមជាលាយលក្ខណ៍អក្សររបស់លោកអ្នកត្រូវតែបានធ្វើឡើងនៅមុនពេល ៖

- គេពិនិត្យមើលការអភិវឌ្ឍន៍នីតិ និងកាយសម្បទារបស់កូនលោកអ្នក ដើម្បីកំណត់មើល ថាតើកូនលោកអ្នកមានពិការភាពឬទេ។
- គេធ្វើការវាយតម្លៃមើលលទ្ធផល និងការវាយតម្លៃមើលវិធីសាស្ត្រលើកូនរបស់លោកអ្នក។
- គេផ្តល់សេវាអន្តរាគមន៍បឋមវ័យជូនកូនលោកអ្នក។
- ប្រើជំនួយ ឬការធានារ៉ាប់រងរបស់រដ្ឋ ឬការធានារ៉ាប់រងឯកជន ដើម្បីបង់ថ្លៃសេវាកម្មនានា។
- ចែករំលែកព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួនលោកអ្នក និងកូនរបស់លោកអ្នកជាមនុស្សដទៃៗ។

> ***ភាសាកំណើត* (Native Language),** *ជាភាសាដែលបានប្រើសម្រាប់មនុស្ស ដែលមិនសូវចេះនិយាយភាសាអង់គ្លេស ដែលមានន័យថាជាភាសាដែលលោកអ្នកប្រើ។ នៅពេលធ្វើការវាយតម្លៃមើលលទ្ធផល និងការវាយតម្លៃមើលវិធីសាស្ត្រ សម្រាប់កូនលោកអ្នក, ភាសាកំណើតមានន័យថាជាភាសាដែលប្រើដោយកូនរបស់លោកអ្នក។ នៅពេលប្រើជាមួយមនុស្សគ ឬមានត្រចៀកធ្ងន់, ខ្វាក់ ឬមើលមិនសូវឃើញ, ឬសម្រាប់មនុស្សនិយាយភាសាគ្មានអក្សរសាស្ត្រសរសេរ, នោះភាសាកំណើតមានន័យថាជារបៀបបែបបទនិយាយប្រស្រ័យទាក់ទងគ្នា ដែលតែងតែប្រើដោយមនុស្សនោះ (ដូចជាភាសាសញ្ញា, អក្សរ* ***ប្រេល្លី*** (Braille) *សម្រាប់មនុស្សពិការភ្នែក, ឬភាសានិយាយផ្ទាល់មាត់ ជាដើម)។*

សេចក្តីយល់ព្រមជាលាយលក្ខណ៍អក្សររបស់លោកអ្នកក៏ត្រូវតែបានផ្តល់ មុនគេផ្តល់សេវាអន្តរាគមន៍បឋមវ័យជូនកូនលោកអ្នក។

បើលោកអ្នកមិនផ្តល់សេចក្តីយល់ព្រម, នោះគេមិនអាចប្រើវិធានការអ្វីមួយ ដើម្បីបង្ខំលោកអ្នកបានទេ។ អាចនិយាយម្យ៉ាងទៀតថា អ្នកសម្របសម្រួលធនធានគ្រួសារ (FRC) ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ មិនអាចប្រើនីតិវិធី សវនាការត្រឹមត្រូវតាមច្បាប់ ដើម្បីបង្ខំលោកអ្នក ឲ្យត្រូវតែផ្តល់សេចក្តីយល់ព្រមទេ។

អ្នកសម្របសម្រួលធនធានគ្រួសារ (FRC), ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ឬបុគ្គលិកដែលមានគុណសម្បត្តិសមរម្យណាម្នាក់គប្បីខិតខំប្រើមធ្យោបាយសមរម្យណាមួយ ដើម្បីធានាថា លោកអ្នក ៖

- ជ្រាបសព្វសេចក្តីអំពីលក្ខណៈនៃការពិនិត្យ, ការវាយតម្លៃមើលលទ្ធផល និងការវាយតម្លៃមើលវិធីសាស្ត្រ ឬសេវាកម្មនានា ដែលអាចនឹងមានបម្រើការជូន។
- ជ្រាបថា កូនលោកអ្នកនឹងមិនអាចទទួលការពិនិត្យ, ការវាយតម្លៃមើលលទ្ធផល និងការវាយតម្លៃមើលវិធីសាស្ត្រ ឬសេវាកម្មនានាបានទេ លើកលែងតែលោកអ្នកបានផ្តល់សេចក្តីយល់ព្រមជាមុនសិន។

ក្នុងមានជាឪពុកម្តាយរបស់កូន ដែលមានលក្ខណសម្បត្តិទទួលជំនួយក្រោមមាត្រា Part C, លោកអ្នកមានសិទ្ធិអាចធ្វើសេចក្តីសម្រេច ថាតើកូន ឬសមាជិកដទៃៗក្នុងគ្រួសារលោកអ្នក យល់ព្រម ឬមិនយល់ព្រមទទួលសេវាអន្តរាគមន៍ណាមួយក្រោមកម្មវិធីនេះ។ លោកអ្នកក៏មានសិទ្ធិអាចបដិសេធចោលនូវសេវាកម្មណាមួយវិញ (លើកលែងតែសេវារដ្ឋបាល ដែលបានតម្រូវក្រោមបទបញ្ជាសម្រាប់ការសម្របសម្រួលធនធានគ្រួសារ) នៅក្រោយពេលបានយកព្រមទទួលវារួចហើយ ដោយគ្មានផលប៉ះពាល់ដល់សេវាអន្តរាគមន៍បឋមវ័យដទៃៗទៀតក្រោមកម្មវិធី ESIT ដែរ។

## បញ្ជីឯកសារ

**ភាពលាក់ការសម្ងាត់**

យោងតាមនីតិវិធីនៃការរក្សាភាពលាក់ការសម្ងាត់លើព័ត៌មានដែលបានបញ្ជាក់ក្នុងឯកសារនេះ, នោះគេត្រូវតែផ្តល់ឱកាសជូនលោកអ្នក ដើម្បីត្រួតពិនិត្យបញ្ជីឯកសារនានា ដែលទាក់ទងនឹងការពិនិត្យសុខភាព, ការវាតម្លៃមើលលទ្ធផល និងការវាយតម្លៃមើលវិធីសាស្ត្រ, ការកំណត់លក្ខណសម្បត្តិ, ការអភិវឌ្ឍន៍ និងការអនុវត្តន៍ផែនការ IFSP, វិធានការសេវាអន្តរាគមន៍បឋមវ័យ, បណ្តឹងពាក់ព័ន្ធកូនលោកអ្នក, និងផ្នែកណាមួយផ្សេងទៀតរបស់កម្មវិធី Part C ដែលពាក់ព័ន្ធទៅនឹងបញ្ជីឯកសាររបស់កូន និងគ្រួសារលោកអ្នក។

អ្នកផ្តល់សេវាអន្តរាគមន៍ម្នាក់ៗត្រូវតែផ្តល់ឱកាស ជូនលោកអ្នកដើម្បីធ្វើការត្រួតពិនិត្យ (ក្នុងអំឡុងម៉ោងធ្វើការ) បញ្ជីឯកសារដែលទាក់ទងនឹងកូន ឬគ្រួសារលោកអ្នក ដែលត្រូវបានប្រមូល, រក្សាទុក ឬប្រើប្រាស់ដោយអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើក្រោមមាត្រា Part C ចាប់ពីពេល ដែលកូនលោកអ្នកបានត្រូវគេបញ្ជូនមករកសេវាអន្តរាគមន៍បឋមវ័យ រហូតដល់ក្រោយពេល ដែលគេលែងត្រូវការទីភ្នាក់ងារចូលរួមមួយនេះ ឲ្យបន្តរក្សាព័ត៌មាន ក្រោមច្បាប់អនុវត្តន៍របស់សហព័ន្ធ ឬរបស់រដ្ឋតទៅទៀត។ អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យត្រូវតែអនុវត្តតាមសេចក្តីស្នើសុំ ដោយគ្មានការពន្យារពេល ដែលមិនចាំបាច់ និងនៅមុនពេលបើកអង្គប្រជុំណាមួយ ដែលពាក់ព័ន្ធផែនការ IFSP ឬសវនាការដែលទាក់ទាងអត្តសញ្ញាណ, ការវាយតម្លៃមើលលទ្ធផល, ការវាយតម្លៃមើលវិធីសាស្ត្រ, ការដាក់កូនឲ្យគេជួយចិញ្ចឹម, ឬវិធានការសេវាកម្មនានាសម្រាប់កូន និងគ្រួសារលោកអ្នក ហើយ, ទោះក្នុងករណីណាក៏ដោយ, មិនត្រូវលើសអំពី 10 ថ្ងៃប្រតិទិន បន្ទាប់ពីសេចក្តីស្នើសុំបានត្រូវធ្វើឡើងឡើយ។ ឱកាសធ្វើការត្រួតពិនិត្យមើលបញ្ជីឯកសារអន្តរាគមន៍បឋមវ័យរួមមាន ៖

- សិទ្ធិទទួលបានការឆ្លើយតបពីអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ចំពោះសេចក្តីស្នើសុំការពន្យល់ និងការបកស្រាយសមរម្យលើបញ្ជីឯកសារនេះ។
- សិទ្ធិស្នើសុំឲ្យអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ផ្តល់បញ្ជីឯកសារនានា ដែលមានផ្ទុកព័ត៌មាន, ប្រសិនបើការខកខានមិនបានផ្តល់សំណៅចម្លងនៃឯកសារទាំងនោះនឹងរារាំងលោកអ្នកពីការអនុវត្តន៍ឱកាសត្រួតពិនិត្យមើលបញ្ជីឯកសាររបស់កូនលោកអ្នកនោះ។
- សិទ្ធិមានអ្នកតំណាង ត្រួតពិនិត្យមើលបញ្ជីឯកសារ។

អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យអាចនឹងសន្មត់ថា លោកអ្នកមានសិទ្ធិអំណាចដើម្បីត្រួតពិនិត្យបញ្ជីឯកសារ ដែលទាក់ទងនឹងកូនលោកអ្នក លើកលែងតែអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើរូបនោះត្រូវបានគេផ្តល់ឯកសារជម្រាបថា លោកអ្នកគ្មានសិទ្ធិអំណាចក្រោមច្បាប់អនុវត្តន៍របស់រដ្ឋ ដែលគ្រប់គ្រងករណីទាំងនោះទេ ដូចជាករណីសិទ្ធិគ្រប់គ្រងកូន, ជួយចិញ្ចឹមក្មេង, អាណាព្យាបាលភាព, បែកប្តីប្រពន្ធ, និងលែងលះប្តីប្រពន្ធ។

អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យម្នាក់ៗគប្បីរក្សាបញ្ជីជាលាយលក្ខណ៍អក្សររបស់ភាគីនានា ដែលមានសិទ្ធិពិនិត្យ, យក ឬប្រើបញ្ជីឯកសារដែលប្រមូលបានក្រោមមាត្រា Part C (លើកលែងតែពិនិត្យ, យក ឬប្រើដោយឪពុកម្តាយ និងបុគ្គលិកដែលមានសិទ្ធិអនុញ្ញាតក្នុងអង្គការជាប់កិច្ចសន្យា ឬអង្គការផ្តល់សេវាបម្រើនោះ), ដែលរួមមានឈ្មោះភាគី, ថ្ងៃទទួលបានសិទ្ធិពិនិត្យ, យក ឬប្រើ, និងគោលបំណង ដែលភាគីណាមួយនោះត្រូវបានផ្តល់សិទ្ធិអនុញ្ញាតឲ្យពិនិត្យ, យក ឬប្រើបញ្ជីឯកសាររបស់ក្មេងរូបនោះ។

ប្រសិនបើបញ្ជីឯកសារអន្តរាគមន៍បឋមវ័យណាមួយនោះមានផ្ទុកព័ត៌មានរបស់ក្មេងលើសពីម្នាក់, នោះលោកអ្នកអាចត្រួតពិនិត្យតែព័ត៌មាន ដែលទាក់ទងនឹងកូនលោកអ្នក ឬរូបលោកអ្នក ឬដើម្បីឲ្យបានយល់ជ្រាបព័ត៌មានជាក់លាក់ណាមួយ ដែលត្រូវបានអនុញ្ញាតប៉ុណ្ណោះ។

អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យម្នាក់ៗ គប្បីផ្តល់ជូនលោកអ្នក, ទៅតាមការស្នើសុំ, នូវបញ្ជីឈ្មោះប្រភេទ និងទីកន្លែង ដែលអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើបានប្រមូល, រក្សាទុក, ឬប្រើបញ្ជីឯកសារអន្តរាគមន៍បឋមវ័យនានា។ អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យអាចនឹងផ្ទាស់ប្តូរថ្លៃថតចម្លងបញ្ជីឯកសារនានា ដែលពួកធ្វើជូនលោកអ្នកក្រោមមាត្រា Part C ប្រសិនបើថ្លៃនោះមិនរារាំងលោកអ្នកអំពីការអនុវត្តិឱកាសរបស់លោកអ្នក ដើម្បីត្រួតពិនិត្យបញ្ជីឯកសារទាំងនោះទេនោះ។ តែទោះយ៉ាងណា, ពួកគេប្រហែលជាមិនយកថ្លៃសម្រាប់ការស្វែងរក ឬការស្រង់យកព័ត៌មានក្រោមមាត្រា Part C ទេ។ បន្ថែមពីនេះ, លោកអ្នកក៏ត្រូវតែទទួលបានសំណៅចម្លងនៃឯកសារវាយតម្លៃមើលលទ្ធផល, ឯកសារវាយតម្លៃមើលវិធីសាស្ត្ររបស់ក្មេង, ឯកសារវាយតម្លៃមើលវិធីសាស្ត្ររបស់គ្រួសារ, និងផែនការ IFSP នីមួយៗយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើទៅបាន នៅបន្ទាប់ពីការប្រជុំ IFSPម្តងៗ។

ប្រសិនបើលោកអ្នកជឿថា ព័ត៌មាននៅក្នុងបញ្ជីឯកសារអន្តរាគមន៍បឋមវ័យ ដែលគេបានប្រមូល, រក្សាទុក ឬប្រើក្រោមមាត្រា Part C នោះមិនត្រឹមត្រូវ ឬអាចនាំឲ្យមានការភាត់ច្រឡំ, ឬបានរំលោភលើសិទ្ធិឯកជន ឬសិទ្ធិផ្សេងៗទៀតរបស់លោកអ្នក ឬកូនរបស់លោកអ្នកដោយប្រការណាមួយ, នោះលោកអ្នកអាចស្នើសុំអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ដែលរក្សាព័ត៌មានទាំងនោះ ឲ្យធ្វើការកែសម្រួលព័ត៌មានទាំងនោះ។

- អ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើរូបនោះត្រូវតែធ្វើសេចក្តីសម្រេចចិត្ត ថាតើពួកគេកែសម្រួល ឬមិនកែសម្រួលព័ត៌មានទាំងនោះ ទៅតាមសេចក្តីស្នើសុំនៅក្នុងរយៈពេលដ៏សមរម្យណាមួយ បន្ទាប់ពីពួកគេបានទទួលសេចក្តីស្នើសុំនោះ។
- ប្រសិនបើអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើរូបនោះបដិសេធ មិនកែសម្រួលព័ត៌មាននោះ ទៅតាមសេចក្តីស្នើសុំរបស់លោកអ្នកទេ, នោះពួកគេត្រូវតែជម្រាបលោកអ្នកអំពីសិទ្ធិស្នើសុំសវនាការ។

> *និយមន័យខាងក្រោមត្រូវបានប្រើនៅក្នុងផ្នែកនេះ ៖ (1) "ការបំផ្លាញ"* ***("destruction")*** *មានន័យថា ការបំផ្លាស់ផាក់ស្តែង ឬការលុបបំបាត់ទិន្នន័យអត្តសញ្ញាញផ្ទាល់ខ្លួនចេញពីព័ត៌មាន ដើម្បីធានាថាទៅថ្ងៃមុខ គេលែងអាចប្រើប្រាស់ទិន្នន័យ ដែលពាក់ព័ន្ធអត្តសញ្ញាណសម្គាល់ខ្លួនទាំងនោះបានទៀតហើយ; (2) "បញ្ជីឯកសារអន្តរាគមន៍បឋមវ័យ"* ***("early intervention records")****, "បញ្ជីឯកសារអប់រំ"* ***("education record(s)")*** *ឬ "បញ្ជីឯកសា"* ***("record(s)")*** *មានន័យថា គ្រប់បញ្ជីឯកសារទាំងអស់ ដែលពាក់ព័ន្ធនឹងកុមារណាម្នាក់ ដែលត្រូវបានតម្រូវឲ្យប្រមូលផ្តុំ, រក្សាទុក, ឬប្រើប្រាស់ក្រោមមាត្រា Part C; និង (3) "ទីភ្នាក់ងារដែលកំពុងចូលរួម ឬ ទីភ្នាក់ងារចូលរួម"* ***("participating agency")*** *មានន័យថា បុគ្គល, ទីភ្នាក់ងារ, អង្គការ, ឬស្ថាប័នណាមួយ ដែលប្រមូលផ្តុំ, រក្សាទុក, ឬប្រើប្រាស់ព័ត៌មានពាក់ព័ន្ធអត្តសញ្ញាណសម្គាល់ខ្លួន ដើម្បីអនុវត្តលក្ខខណ្ឌតម្រូវនានាក្នុងកម្មវិធី Part C។ ទីភ្នាក់ងារដែលកំពុងចូលរួមគឺរួមមាន ទីភ្នាក់នាំមុខរបស់រដ្ឋ, អ្នកផ្តលសេវាអន្តរាគមន៍បឋមវ័យម្នាក់ៗ ដែលផ្តល់សេវា Part C (រួមមានសេវាសម្របសម្រួល, សេវាវាយតម្លៃមើលលទ្ធផល, សេវាវាយតម្លៃមើលវិធីសាស្ត្រ, និងសេវា Part C ដទៃៗទៀត)។ វាមិនរាប់បញ្ចូលទាំងប្រភពនៃការបញ្ជូនដាបឋម ឬទីភ្នាក់ងាររបស់រដ្ឋ ឬទីភ្នាក់ងារឯកជន ដែលផ្តល់ប្រាក់ជំនួយទ្រទ្រង់សេវាអន្តរាគមន៍បឋមទេ។*

អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យត្រូវតែផ្តល់, ទៅតាមសេចក្តីស្នើសុំ, នូវឱកាសឡើងសវនាការ ដើម្បីជជែកតវ៉ាថា ព័ត៌មានក្នុងបញ្ជីឯកសារអន្តរាគមន៍បឋមវ័យ ពិតជាមិនត្រូវ, អាចនាំឲ្យមានការភាន់ច្រឡំ, ឬបានរំលោភលើសិទ្ធិឯកជន ឬសិទ្ធិដទៃៗទៀតរបស់លោកអ្នក និងកូនលោកអ្នក ដោយប្រការណាមួយ។ លោកអ្នកអាចស្នើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ក្រោមនីតិវិធី ឬនីតិវិធីសវនាការ Part C ដែលស្របតាមបទបញ្ញានៃ**ច្បាប់សិទ្ធិអប់រំគ្រួសារ និងសទ្ធិឯកជន** (Family Educational Rights and Privacy Act, FERPA) នៅ 34 CFR 99.22។

- ប្រសិនបើ, យោងតាមលទ្ធផលសវនាការ, អ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យសម្រេចថា ព័ត៌មាននោះពិតជាមិនត្រឹមត្រូវ, អាចនាំឲ្យមានការភាន់ច្រឡំ, ឬបានល្មើសលើសិទ្ធិឯកជន ឬសិទ្ធិដទៃៗរបស់លោកអ្នក ឬរបស់កូនលោកអ្នកមែន, នោះពួកគេត្រូវតែកែសម្រួលព័ត៌មាននោះទៅតាមសេចក្តីស្នើសុំ ហើយបន្ទាប់មក ពួកគេត្រូវតែប្រាប់លោកអ្នក ឲ្យបានជ្រាបអំពីសេចក្តីនេះជាលាយលក្ខណ៍អក្សរ។
- ប្រសិនបើ, យោងតាមលទ្ធផលសវនាការ, អ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើសម្រេចថា ព័ត៌មាននោះពុំមានការខុសឆ្គង, មិននាំឲ្យភាន់ច្រឡំ, ឬមិនបានរំលោភលើសិទ្ធិឯកជន ឬសិទ្ធិដទៃៗរបស់លោកអ្នក ឬរបស់កូនលោកអ្នកដោយប្រការណាមួយទេ, នោះពួកគេត្រូវតែជម្រាបប្រាប់លោកអ្នកអំពីសិទ្ធិធ្វើលិខិតពន្យល់ ហើយដាក់តម្កល់ក្នុងបញ្ជីឯកសាររបស់កូនលោកអ្នក ដោយបញ្ជាក់ថា លោកអ្នកមិនយល់ស្របតាមសេចក្តីសម្រេចរបស់អ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើទេ ដ្បិតវាខុសយ៉ាងនេះមួយ យ៉ាងនោះមួយ។
- សេចក្តីពន្យល់ដែលបានដាក់តម្កល់ក្នុងបញ្ជីឯកសាររបស់កូនលោកអ្នក ក្រោមនីតិវិធីទាំងនេះត្រូវតែបានរក្សាដោយអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ទុកជាផ្នែកនៃបញ្ជីឯកសាររបស់កូនលោកអ្នក ដរាបណាបញ្ជីឯកសារ ឬព័ត៌មានត្រង់ផ្នែកដែលលោកអ្នកបានតវ៉ានោះ ត្រូវបានរក្សាទុកដោយអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើរូបនោះ។
- ប្រសិនបើបញ្ជីឯកសាររបស់កូនលោកអ្នក ឬព័ត៌មានត្រង់ផ្នែកដែលលោកអ្នកបានតវ៉ានោះត្រូវបានបើកបញ្ចេញដោយអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាបម្រើឲ្យទៅភាគីណាមួយ, នោះសេចក្តីពន្យល់របស់លោកអ្នកក៏ត្រូវតែបានបើកបញ្ចេញឲ្យទៅភាគីនោះផងដែរ។

<u>**សេចក្តីយល់ព្រមនៅមុនពេលបើកបញ្ចេញព័ត៌មាន**</u>

គេត្រូវតែមានសេចក្តីយល់ព្រមពីឪពុកម្តាយជាមុន ទើបគេអាច ៖

- បើកបញ្ចេញព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួន ជូនទៅជនណាម្នាក់ក្រៅពីមន្ត្រីរបស់អង្គការជាប់កិច្ចសន្យា អង្គការផ្តល់សេវាបម្រើ ដែលប្រមូល, រក្សា, ឬប្រើព័ត៌មានក្រោមមាត្រា Part C, លើកលែងតែត្រូវបានផ្តល់សិទ្ធិអនុញ្ញាត ឲ្យធ្វើដូច្នោះបានក្រោមច្បាប់ Part C (34 CFR 303.414) និង FERPA (34 CFR 99.31); ឬ
- ប្រើព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួន សម្រាប់គោលបំណងណាមួយក្រៅការបំពេញតាមលក្ខខណ្ឌតម្រូវក្រោមមាត្រា Part C។

ព័ត៌មានចេញពីបញ្ជីឯកសារអន្តរាគមន៍បឋមវ័យរបស់កូនលោកអ្នកមិនអាចបើកបញ្ចេញដោយអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យឲ្យទៅទីភ្នាក់ងារណាមួយ ដោយគ្មានសេចក្តីយល់ព្រមពីលោកអ្នកបានទេ លើកលែងតែអ្នកជាប់កិច្ចសន្យា ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនោះ បានទទួលសិទ្ធិអនុញ្ញាត ឲ្យធ្វើដូច្នោះក្រោមច្បាប់ FERPA។ ប្រសិនបើលោកអ្នកបដិសេធមិនផ្តល់សេចក្តីយល់ព្រមជូនពួកគេទេ, នោះអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនឹងប្រើនីតិវិធី ដែលទាក់ទងនឹងការបដិសេធនោះ, ដូចជាការពន្យល់ប្រាប់លោកអ្នកឲ្យបានជ្រាបថា តើការមិនផ្តល់សេចក្តីយល់ព្រមរបស់លោកអ្នកអាចប៉ះពាល់ដល់សមត្ថភាពកូនរបស់លោកអ្នក ក្នុងការទទួលសេវាអន្តរាគមន៍បឋមវ័យយ៉ាងណា, ដរាបណានីតិវិធីនេះមិនអាចមានឥទ្ធិពលលុបលើសិទ្ធិរបស់លោកអ្នកក្នុងការបដិសេធមិនផ្តល់សេចក្តីយល់ព្រមទេនោះ។

ក្រោមមាត្រា Part C, ESIT ត្រូវបានតម្រូវឲ្យបើកបញ្ចេញឈ្មោះ និងខែថ្ងៃឆ្នាំកំណើតរបស់កូនលោកអ្នក និងព័ត៌មានសម្រាប់គេទាក់ទងមកលោកអ្នក (រួមមានឈ្មោះ, អាសយដ្ឋាន, និងលេខទូរស័ព្ទរបស់លោកអ្នក) ទៅឲ្យទីភ្នាក់ងារអប់រំរបស់រដ្ឋ (ការិយាល័យស្នងការអប់រំសាធារណៈ (Office of Superintendent of Public Instruction)) និងទីភ្នាក់ងារអប់រំមូលដ្ឋាន (មណ្ឌលសិក្សាធិការនៃសាលាមូលដ្ឋាន (local school district)) ដែលកូនលោកអ្នករស់នៅ ដោយពុំចាំបាច់មានសេចក្តីយល់ព្រមពីលោកអ្នកទេ។ គេត្រូវការព័ត៌មានទាំងនេះដើម្បីសម្គាល់អត្តសញ្ញាណកុមារទាំងអស់ ដែលមានលក្ខណសម្បត្តិទទួលសេវាក្រោមមាត្រា Part B នៃច្បាប់ IDEA។

នីតិវិធីការពារខាងក្រោមនេះត្រូវតែបានធ្វើឡើង ដើម្បីធានាអំពីភាពលាក់ការសម្ងាត់លើបញ្ជីឯកសារ ៖

- អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យម្នាក់ៗត្រូវតែការពារភាពលាក់ការសម្ងាត់លើព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួនរបស់លោកអ្នក គ្រប់ដំណាក់នៃកាលប្រមូលផ្តុំ, រក្សាទុក, ស្តុកទិន្នន័យទុក, បើកបញ្ចេញ, និងបំផ្លាញចោល។
- មន្ត្រីម្នាក់ក្នុងអង្គការផ្តល់សេវាអន្តរាគមន៍បឋមវ័យនីមួយៗទទួលខុសត្រូវលើការធានារក្សាភាពលាក់ការសម្ងាត់លើព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួន។
- បុគ្គលិកគ្រប់រូប ដែលធ្វើការប្រមូលផ្តុំ ឬប្រើព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួន ត្រូវតែបានទទួលការបណ្តុះបណ្តាល ឬការណែនាំអំពីច្បាប់ និងនីតិវិធីគ្រប់គ្រងទាំងឡាយនៃមាត្រា Part C របស់រដ្ឋវ៉ាស៊ីនតោន ដែលប្រតិបត្តិតាមច្បាប់ IDEA និងច្បាប់ FERPA។
- អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យម្នាក់ៗត្រូវតែរក្សា, សម្រាប់ការត្រួតពិនិត្យសាធារណៈ, នូវបញ្ជីឈ្មោះ និងតំណែងការងាររបស់និយោជិត ដែលធ្វើការនៅក្នុងទីភ្នាក់ងារបច្ចុប្បន្ន ដែលមានសិទ្ធិចេញចូលប្រើប្រាស់ព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួនរបស់អតិថិជន។
- អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យម្នាក់ៗត្រូវតែជម្រាបប្រាប់ឪពុកម្តាយឲ្យបានជ្រាប នៅពេលណាពួកគេលែងត្រូវការព័ត៌មានអត្តសញ្ញាណសម្គាល់ខ្លួនរបស់អតិថិជន ដែលពួកគេបានប្រមូលផ្តុំ, រក្សាទុក, ឬប្រើប្រាស់ ដើម្បីនឹងផ្តល់សេវាជូនកូន ឬគ្រួសារលោកអ្នកក្រោមមាត្រា Part C, វិធានការ GEPA ក្នុងមាត្រា 20 USC 1232f, និងច្បាប់ EDGAR, 34 CFR ផ្នែកទី 76 និងទី 80 ទៀតហើយនោះ។
- នៅពេលណាគេឈប់ត្រូវការព័ត៌មាននេះ សម្រាប់ផ្តល់វិធានការសេវាជូនកូន ឬគ្រួសារលោកអ្នកតទៅទៀតហើយនោះ, នោះពួកគេត្រូវតែបំផ្លាញព័ត៌មានទាំងនោះចោល ទៅការស្នើសុំរបស់ឪពុកម្តាយ។

បញ្ជីឯកសារអចិន្ត្រៃយ៍ដែលមានផ្ទុកឈ្មោះ, ខែថ្ងៃឆ្នាំកំណើតរបស់កូន, ព័ត៌មានសម្រាប់គេទាក់ទងឪពុកម្តាយ (ដែលរួមមានអាសយដ្ឋាន និងលេខទូរស័ព្ទ), ឈ្មោះអ្នកសម្របសម្រួលធនធាន (FRC), និងឈ្មោះអ្នកផ្តល់សេវាអត្តរាគមន៍បឋមវ័យ, និងទិន្នន័យអំពីចាកចេញ (ដែលរួមមានឆ្នាំ និងអាយុនៅពេលចាកចេញពីកម្មវិធីនេះ, និងកម្មវិធីដទៃៗទៀត ដែលក្មេងបានទទួលរហូតមកដល់ថ្ងៃចាកចេញ) អាចនឹងត្រូវគេរក្សាទុកដោយគ្មានពេលវេលាកំណត់។

## និតិវិធីដោះស្រាយវិវាទ

បើលោកអ្នកមានបញ្ហាអ្វីមួយពាក់ព័ន្ធកម្មវិធីអន្តរាគមន៍បឋមវ័យរបស់កូនលោកអ្នក, សូមអញ្ជើញពិភាក្សាជាមួយបុគ្គលិក FRC ឬ IFSP ឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។ កម្មវិធី ESIT ស្នើសុំលោកអ្នក អញ្ជើញដោះស្រាយបញ្ហា ឲ្យទាន់ពេលដែលវានៅតូច។ ប៉ុន្តែ បើបញ្ហាមិនអាចដោះស្រាយក្រៅផ្លូវការបានទេ, នោះយើងមាននីតិវិធីដោះស្រាយតាមផ្លូវការជូនទៅតាមលំដាប់លំដោយ។

បើលោកអ្នកមិនយល់ស្របជាមួយអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យអំពីបញ្ហាអត្តសញ្ញាណកូន, ការវាយតម្លៃមើលលទ្ធផល, ការដាក់កូនឲ្យគេជួយចិញ្ចឹម, ឬវិធានការសេវាអន្តរាគមន៍បឋមវ័យណាមួយ ដែលគេផ្តល់ជូនកូន ឬគ្រួសារលោកអ្នក, នោះលោកអ្នកអាចស្នើសុំសមត្ថកិច្ចពាក់ព័ន្ធ ឲ្យជួយដោះស្រាយបញ្ហានានារបស់លោកអ្នក ទៅតាមពេលវេលាសមរម្យណាមួយ។

**ខាងក្រោមនេះគឺជានីតិវិធីផ្លូវការបីប្រភេទ ដែលមានបម្រើការជូនលោកអ្នក សម្រាប់ដោះស្រាយវិវាទ។ នីតិវិធីទាំងនេះរួមមាននីតិវិធីផ្សះផ្សា, នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង, និងនីតិវិធីបណ្តឹងរដ្ឋបាល។**

## នីតិវិធីផ្សះផ្សា (Mediation)

នីតិវិធីផ្សះផ្សាផ្តល់ជូនលោកអ្នកនូវឱកាស ដើម្បីដោះស្រាយភាពមិនចុះសម្រុងគ្នា តាមមធ្យោបាយមិនចងសត្រូវ។ វាគឺជានីតិវិធីស្ម័គ្រចិត្ត ហើយត្រូវតែមានការយល់ព្រមពីគូភាគីទាំងសងខាង ដោយគ្មានមានការបង្ខិតបង្ខំ។

ទីភ្នាក់ងារនាំមុខរបស់រដ្ឋអាចបង្កើតនីតិវិធី ដើម្បីផ្តល់ជូនឪពុកម្តាយ និងបណ្តាអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យ ដែលជ្រើសរើសមិនប្រើនីតិវិធីផ្សះផ្សា នូវឱកាសជួប, នៅកន្លែងដែលងាយស្រួលសម្រាប់លោកអ្នក, ភាគីដែលមិនស្វែងរកប្រយោជន៍(អ្នកផ្សះផ្សាឥតលំអៀង), ដែលចុះកិច្ចសន្យាធ្វើការឲ្យអង្គការដោះស្រាយវិវាទ, ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលមាតាបិតា និងព័ត៌មាន, ឬមជ្ឈមណ្ឌលធនធានមាតាបិតាសហគមន៍ក្នុងរដ្ឋ, ដើម្បីពន្យល់ប្រាប់អំពីអត្ថប្រយោជន៍នៃនីតិវិធីផ្សះផ្សា ហើយជួយលើកទឹកចិត្តឲ្យប្រើនីតិវិធីផ្សះផ្សា។

នីតិវិធីផ្សះផ្សាត្រូវតែបានបញ្ចប់ជាស្ថាពរ ទៅតាមពេលវេលាកំណត់សមរម្យណាមួយ នៅក្រោយថ្ងៃដែលទីភ្នាក់ងារនាំមុខរបស់រដ្ឋបានទទួលសេចក្តីស្នើសុំការផ្សះផ្សា ហើយមិនអាចប្រើដើម្បីបដិសេធ ឬពន្យារសិទ្ធិរបស់លោកអ្នក ពីការស្នើសុំនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ឬបដិសេធសិទ្ធិដទៃៗទៀតរបស់លោកអ្នកក្រោមមាត្រា Part C ឡើយ។

ការផ្សះផ្សានឹងត្រូវបានដាក់ពេលធ្វើ ឲ្យទាន់ពេលវេលាសមរម្យណាមួយ ហើយត្រូវតែធ្វើនៅកន្លែងណាមួយ ដែលងាយស្រួលសម្រាប់ភាគីទាំងសងខាង។ អ្នកផ្សះផ្សាដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងឥតលំអៀង, ដែលបានទទួលការបណ្តុះបណ្តាលក្នុងការរកមធ្យោបាយផ្សះផ្សា, នឹងជួបជាមួយភាគីទាំងសងខាងដើម្បីជួយរកដំណោះស្រាយវិវាទក្រៅផ្លូវការ ក្នុងបរិយាកាសមិត្តភាព មិនមែនជាគូទំនាស់។

ទីភ្នាក់ងារនាំមុខរបស់រដ្ឋរក្សាទុកបញ្ជីឈ្មោះរបស់ពួកអ្នកផ្សះផ្សាមានគុណសម្បត្តិគ្រប់គ្រាន់ឥតលំអៀង ដែលមានចំណេះដឹងអំពីច្បាប់ និងបទបញ្ជាទាក់ទងវិធីការសេវាអន្តរាគមន៍បឋមវ័យសម្រាប់ទារក និងកូនក្មេងអាយុពីរបីឆ្នាំ ដែលមានពិការភាព និងគ្រួសាររបស់ពួកគេ។ អ្នកផ្សះផ្សាត្រូវតែបានត្រូវជ្រើសរើសដោយព្រាវ, ដោយផ្លាស់ប្តូរគ្នាម្តងម្នាក់, ឬដោយឥតលំអៀង។ ទីភ្នាក់ងារនាំមុខរបស់រដ្ឋត្រូវទទួលខុសត្រូវលើថ្លៃផ្សះផ្សា សរុបទាំងថ្លៃប្រជុំជំនុំគ្នា ដើម្បីលើកទឹកចិត្តឲ្យភាគីទាំងសងខាងផ្សះផ្សាផង។

ប្រសិនបើវិវាទមិនចុះសម្រុងគ្នាបានដោះស្រាយជាស្ថាពរ តាមរយៈការផ្សះផ្សា, នោះភាគីទាំងសងខាងត្រូវតែធ្វើកិច្ចព្រមព្រៀងអនុវត្តន៍កាតព្វកិច្ចផ្លូវច្បាប់មួយ ដែលពណ៌នាអំពីសេចក្តីសម្រេចលើដំណោះស្រាយ ហើយបញ្ជាក់ថា គ្រប់កិច្ចពិភាក្សាទាំងអស់ដែលបានធ្វើឡើងនៅក្នុងអង្គជំនុំផ្សះផ្សា ត្រូវតែបានរក្សាទុកជាកិច្ចការសម្ងាត់ ហើយមិនអាចត្រូវភាគីណាមួយ យកទៅប្រើធ្វើជាភស្តុតាងដាប់បន្ទុកនៅក្នុងសវនាការ ឬក្នុងនីតិវិធីរដ្ឋប្បវេណីលើកក្រោយៗបានទេ។ កិច្ចព្រមព្រៀងនេះត្រូវតែចុះហត្ថលេខាដោយលោកអ្នក និងដោយអ្នកតំណាងរបស់ទីភ្នាក់ងារនាំមុខរបស់រដ្ឋរូបណា ដែលមានសិទ្ធិសម្រេចភ្ជាប់ទីភ្នាក់ងារ ដែលខ្លួនតំណាង ទៅនឹងកាតព្វកិច្ចផ្លូវច្បាប់នេះ។ កិច្ចព្រមព្រៀងផ្សះផ្សាដែលបានចុះហត្ថលេខាជាលាយលក្ខណ៍អក្សរនេះ គឺមានតម្លៃប្រតិបត្តិក្នុងតុលាការរដ្ឋ ដែលមានសុត្តាធិការអនុវត្តច្បាប់ ឬតុលាការតំបន់របស់សហរដ្ឋបានគ្រប់ទីកន្លែង និងពេលវេលា។

ទោះក្នុងកាលៈទេសៈណាក៏ដោយ, នីតិវិធីផ្សះផ្សាមិនហាមឃាត់លោកអ្នក ពីការស្នើសុំនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងទេ។ លោកអ្នកអាចដាក់ពាក្យស្នើសុំនីតិវិធីផ្សះផ្សា និងនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ក្នុងពេលដំណាលគ្នាបាន ដូចបានពណ៌នាជូនខាងក្រោមនេះ។

## សវនាការត្រឹមត្រូវតាមច្បាប់ឥលលំអៀង (Impartial Due Process Hearings)

សវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងគឺជានីតិវិធីផ្លូវការមួយក្រោមអធិបតីភាពរបស់មន្ត្រីសវនាការឥតលំអៀងណាមួយរូប ហើយគឺជាជម្រើសមួយ សម្រាប់បណ្តាគ្រួសារ ដែលស្វែងរកការដាក់ពាក្យបណ្តឹងឯកត្តជន តាងនាមឲ្យកូនរបស់ខ្លួន។

សវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងត្រូវតែបានបញ្ចប់ជាស្ថាពរ, ហើយបានធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ, នៅក្នុងរយៈពេល 30 ថ្ងៃប្រតិទិន ចាប់ពីថ្ងៃទទួលបានសេចក្តីស្នើសុំ។ នីតិវិធីផ្សះផ្សា, ប្រសិនបើត្រូវបានស្នើសុំ, ត្រូវតែបានធ្វើឡើងនៅក្នុងនៅក្នុងរយៈពេល 30 ថ្ងៃប្រតិទិនដូចគ្នានេះដែរ)។ មន្ត្រីសវនាការត្រូវបានចាត់តាំង ឲ្យធ្វើអធិបតីលើនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងនេះ។

មន្ត្រីសវនាការត្រូវតែមានចំណេះដឹងអំពីវិធានការនៅក្នុងមាត្រា Part C និងអំពីតម្រូវការ និងសេវាកម្ម ដែលមានបម្រើការជូនកុមារ និងក្រុមគ្រួសាររបស់ពួកគេ ដែលមានលក្ខណសម្បត្តិទទួលជំនួយទាំងនេះ ហើយត្រូវអនុវត្តករណីយកិច្ចដូចតទៅ ៖

- ស្តាប់បទបង្ហាញព័ត៌មានពាក់ព័ន្ធនឹងការតវ៉ា, ពិនិត្យវិនិច្ឆ័យមើលព័ត៌មានទាំងអស់ ដែលពាក់ព័ន្ធនឹងបញ្ហា ហើយត្រូវស្វែងរកដំណោះស្រាយសមស្របណាមួយជូនភាគីវិវាទទាំងសងខាង ឲ្យទាន់ពេលសមរម្យ។
- ផ្តល់ឯកសារចំណាត់ការ ដោយមានភាគីរដ្ឋជាអ្នកចេញថ្លៃ ដោយសរុបទាំងលិខិតសម្រេចជាលាយលក្ខណ៍អក្សរផត។

> ***អំពីអ្នកផ្សះផ្សា និងមន្ត្រីសវនាការ. . .***
> *អ្នកផ្សះផ្សា និងមន្ត្រីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវតែ "ឥតលំអៀង" ។ ឥតលំអៀងមានន័យថា ជនដែលត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកផ្សះផ្សា ឬមន្ត្រីសវនាការនោះ ៖ (1) មិនមែនជាបុគ្គលិករបស់ទីភ្នាក់ងារនាំមុខរបស់រដ្ឋ ឬរបស់ទីភ្នាក់ងារផ្តល់សេវាអន្តរាគមន៍បឋមវ័យ ដែលបានជាប់ពាក់ព័ន្ធក្នុងសេវាអន្តរាគមន៍បឋមវ័យ ដែលពួកគេកំពុងតែផ្តល់នោះ, ឬសេវាដទៃៗទៀត, ឬសេវាថែទាំសុខភាពរបស់កុមាររូបនោះ; និង (2) មិនមានជាប់ពាក់ព័ន្ធផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍វិជ្ជាជីវៈដែលអាចនាំឲ្យមានទំនាស់ដល់វត្ថុវិស័យភាពរបស់គាត់ក្នុងការអនុវត្តន៍នីតិវិធីនេះ។ ជនដែលមានគុណសម្បត្តិគ្រប់គ្រាន់ ធ្វើជាអ្នកផ្សះផ្សា ឬមន្ត្រីសវនាំការគឺត្រូវតែមិនមែនជាបុគ្គលិករបស់ទីភ្នាក់ងារនាមុខរបស់រដ្ឋ, ឬបុគ្គលិករបស់ទីភ្នាក់ងារផ្តល់សេវាអន្តរាគមន៍បឋមវ័យ ដោយប្រការណាមួយសោះឡើយ ពីព្រោះជនរូបនេះត្រូវបានជួលដោយទីភ្នាក់ងារ ឬកម្មវិធីនេះ ដើម្បីអនុវត្តវិធានការផ្សះផ្សា ឬវិធានការសវនាការត្រឹមត្រូវតាមផវច្យាប់។*

នៅក្រោមមាត្រា Part C, លោកអ្នកមានសិទ្ធិ ដូចបានជម្រាបជូនខាងក្រោមនេះ ក្នុងការស្នើសុំសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ដែលអនុវត្តក្រោមនីតិវិធីទាំងនេះ។

- អមដំណើរ និងផ្តល់យោបល់ដោយមេធាវី (ដោយលោកអ្នកជាអ្នកចេញថ្លៃ) និងដោយបុគ្គល(នានា) ដែលមានចំណេះដឹង ឬជំនាញពិសេសអំពីសេវាអន្តរាគមន៍បឋមវ័យសម្រាប់កុមារ ដែលមានលក្ខណសម្បត្តិទទួលជំនួយក្រោមមាត្រា Part C (ដោយលោកអ្នកជាអ្នកចេញថ្លៃ)។
- បង្ហាញភស្តុតាង និងជជែកតតាំង, សួរសាក្សីរបស់ភាគីរបស់ម្ខាងទៀត, និងផ្តល់សាក្សីរបស់ខ្លួន។
- ហាមឃាត់កុំឲ្យគេការបង្ហាពាភស្តុតាងណាមួយនៅក្នុងសវនាការ ដែលគេមិនបានបង្ហាញដល់លោកអ្នកជាមុនយ៉ាងតិចណាស់ប្រាំថ្ងៃប្រតិទិន មុនថ្ងៃសវនាការ។
- ទទួលបានសំណៅកំណត់ហេតុសវនាការ តាមពាក្យពេចន៍គ្រង់ៗ ជាទម្រង់ក្រដាសលាយលក្ខណ៍អក្សរ ឬទម្រង់អឡិចត្រូនិច ដោយឥតគិតថ្លៃ។
- ទទួលបានសំណៅចម្លងនៃអង្គហេតុ និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដោយឥតគិតថ្លៃ។

សវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ដែលបានពណ៌នានៅក្នុងនីតិវិធីទាំងនេះ ត្រូវតែអនុវត្តនៅពេល និងទីកន្លែងណាដែលបង្កភាពងាយស្រួលដល់លោកអ្នក។ មិនហួសពី 30 ថ្ងៃប្រតិទិនក្រោយពេលទីភ្នាក់ងារនាំមុខរបស់រដ្ឋបានទទួលពាក្យបណ្តឹងរបស់លោកអ្នក, នោះសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងត្រូវតែបញ្ចប់ ហើយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមួយច្បាប់ត្រូវតែបានផ្ញើជូនភាគីនីមួយៗ។ មន្ត្រីសវនាការអាចអនុញ្ញាតឲ្យមានការពន្យារពេលលើសពី 30 ថ្ងៃ នៅពេលមានភាគីណាម្ខាងស្នើសុំ។ ប្រសិនបើមានភាគីណាម្ខាងមិនពេញចិត្តនឹងអង្គហេតុ ហើយនិងសេចក្តីសម្រេចរបស់សវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀងនេះ, ភាគីនោះអាចបន្តដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីទៅកាន់តុលាការរដ្ឋ ឬតុលាការសហព័ន្ធទៀត។

នៅក្នុងរយៈពេលព្យួរនីតិវិធីណាមួយ ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងត្រឹមត្រូវតាមច្បាប់, លើកលែងតែបានយល់ព្រមយ៉ាងណាមួយរវាងអ្នកផ្តល់សេវាអន្តរគមន៍បឋមវ័យ និងលោកអ្នក, ពុំនោះកូន និងគ្រួសារលោកអ្នកនឹងបន្តទទួលសេវាអន្តរាគមន៍បឋមវ័យសមស្របណាមួយជាធម្មតា ទៅតាមសេចក្តីចែងក្នុងផែនការ IFSP ដែលលោកអ្នកបានផ្តល់ការយល់ព្រមរួចមកហើយនោះ។

ប្រសិនបើពាក្យបណ្តឹងនេះពាក់ព័ន្ធនឹងកាដាក់ពាក្យសុំសេវាលើកដំបូងក្រោមមាត្រា Part C, នោះកូន និងគ្រួសារលោកអ្នកត្រូវតែទទួលបានសេវាទាំងឡាយណា ដែលមិនស្ថិតក្នុងវិវាទ។

## បណ្តឹងរដ្ឋបាល (Administrative Complaints)

បន្ថែមលើនីតិវិធីផ្សះផ្សា និងនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ដែលបានពណ៌នាជូនខាងលើ, បុគ្គល ឬអង្គការ ដោយរួមទាំងអស់អ្នកដែលមកពីរដ្ឋក្រៅៗផង អាចដាក់បណ្តឹងលាយលក្ខណ៍អក្សរ ដោយមានការហត្ថលេខា ដើម្បីប្រឆាំងទីភ្នាក់ងារសាធារណៈ ឬអ្នកផ្តល់សេវាបម្រើឯកជន ដោយសរុបទាំងអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យណាមួយផង ដែលកំពុងប្រព្រឹត្តល្មើសលើលក្ខខណ្ឌតម្រូវរបស់កម្មវិធី Part C។ ទីភ្នាក់ងារនាំមុខរបស់រដ្ឋផ្សព្វផ្សាយអំពីនីតិវិធីដោះស្រាយបណ្តឹងនេះ ដល់ឪពុកម្តាយ នឹងបុគ្គលពាក់ព័ន្ធដទៃទៀតទូទាំងរដ្ឋ ដោយរួមមានទាំងការបើកមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មានមាតាបិតា, ទីភ្នាក់ងារការពារ និងគាំពារ, និងអង្គការពាក់ព័ន្ធដទៃៗមួយចំនួនទៀត។

ពាក្យបណ្តឹងត្រូវតែមានអត្ថន័យខ្លឹមសារ និងបានដាក់បញ្ចូលនូវវត្ថុតាងដូចតទៅនេះ ៖

- សេចក្តីថ្លែងការណ៍ដែលចោទប្រកាន់ថា ទីភ្នាក់ងារនាំមុខ, ទីភ្នាក់ងារសាធារណៈ, ឬអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យណាមួយនោះ បានប្រព្រឹត្តល្មើសលើលក្ខខណ្ឌតម្រូវរបស់កម្មវិធី Part C។
- អង្គហេតុ(ឬហេតុការណ៍) ដែលទ្រទ្រង់សេចក្តីថ្លែងការណ៍របស់លោកអ្នក។
- ហត្ថលេខា និងព័ត៌មានសម្រាប់គេទាក់ទងទៅបុគ្គលដែលដាក់ពាក្យបណ្តឹងនេះ។
- ប្រសិនបើបទល្មើសដែលកំពុងត្រូវបានចោទប្រកាន់នេះ

  ពាក់ព័ន្ធនឹងក្មេងជាក់លាក់ណាម្នាក់, នោះគឺ ៖

  – ឈ្មោះ និងអាសយដ្ឋានរស់នៅរបស់ក្មេង។

  – ឈ្មោះអ្នកជាប់កិច្ចសន្យាផ្តល់សេវាអន្តរាគមន៍បឋមវ័យ ឬឈ្មោះអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យរបស់ក្មេង។

  – សេចក្តីពណ៌នាអំពីលក្ខណៈនៃបញ្ហារបស់ក្មេង ដោយដាក់បញ្ចូលទាំងអង្គហេតុ ដែលពាក់ព័ន្ធនឹងបញ្ហានោះផង។

  – ដំណោះស្រាយដែលគេបានស្នើឡើង ដើម្បីដោះស្រាយបញ្ហា ទៅតាមការពិតជាក់ស្តែងដែលបានអ្នកដាក់បណ្តឹងបានដឹងនៅក្នុងពេលដាក់បណ្តឹងនេះ

**បណ្ដឹងរដ្ឋបាលត្រូវតែបានដាក់ និងទទួលដោយទីភ្នាក់ងារនាំមុខរបស់រដ្ឋនៅក្នុងរយៈពេលមួយ (1) ឆ្នាំពីថ្ងៃ ដែលបទល្មើសដាប់ចោទនោះបានកើតឡើង។** បុគ្គល ឬទីភ្នាក់ងារដែលដាក់បណ្ដឹងនេះត្រូវតែផ្ដល់សំណៅចម្លងនៃបណ្ដឹងនេះ ដល់អ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យ ដែលផ្ដល់សេវាបម្រើជូនក្មេងរូបនោះ នៅក្នុងពេលជាមួយគ្នា ដែលពាក្យបណ្ដឹងនេះត្រូវបានដាក់ប្ដឹងទៅទីភ្នាក់ងារនាំមុខរបស់រដ្ឋ។

នៅពេលណាទីភ្នាក់ងារនាំមុខរបស់រដ្ឋបានទទួលពាក្យបណ្ដឹងនេះហើយ, នោះគេមានពេល 60 ថ្ងៃប្រតិទិន ដើម្បី ៖

- ធ្វើការស៊ើបអង្កេតដោយឯករាជ្យដល់កន្លែង ប្រសិនបើទីភ្នាក់ងារនាំមុខរបស់រដ្ឋយល់ឃើញថា ការស៊ើបអង្កេតនេះមានការចាំបាច់។
- ផ្ដល់ជូនបុគ្គល ឬទីភ្នាក់ងារដែលដាក់បណ្ដឹងនូវឱកាសដើម្បីដាក់ព័ត៌មានបន្ថែម, ទោះបើជាព័ត៌មានតាមការនិយាយប្រាប់ផ្ទាល់មាត់ ឬសំណេរលាយលក្ខណ៍អក្សរក្ដី, ស្ដីពីការចោទប្រកាន់ក្នុងបណ្ដឹងនេះ។
- ផ្ដល់ជូនទីភ្នាក់ងារ/អ្នកផ្ដល់សេវាបម្រើ ដែលជាប់ចោទនូវឱកាសដើម្បីធ្វើការឆ្លើយតបនឹងបណ្ដឹងនេះ ដោយរួមទាំងការដាក់សំណើ ដើម្បីដោះស្រាយបណ្ដឹងនេះ និងឱកាស ឲ្យភាគីទាំងអស់ធ្វើការផ្សះផ្សាគ្នាផង ទៅតាមឆន្ទានុសិទ្ធិរបស់ទីភ្នាក់ងារនាំមុខរបស់រដ្ឋ។
- ពិនិត្យពិច័យមើលព័ត៌មានពាក់ព័ន្ធទាំងអស់ ហើយធ្វើការវិនិច្ឆ័យឯករាជ្យ ថាតើបទល្មើសលើលក្ខខណ្ឌតម្រូវរបស់កម្មវិធី Part C ដែលបានជាប់ចោទនោះ ពិតជាបាន ឬមិនបានកើតឡើង។
- ចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ជូនបុគ្គលដែលដាក់បណ្ដឹង ដើម្បីបញ្ជាប់ប្រាប់អំពីបទចោទប្រកាន់នីមួយៗក្នុងបណ្ដឹងនេះ ហើយនៅក្នុងនោះមានផ្ទុកនូវអង្គហេតុនានា និងសេចក្ដីសន្និដ្ឋានអំពីអង្គហេតុព្រមទាំងមូលហេតុទាំងឡាយ ដែលទីភ្នាក់ងារនាំមុខរបស់រដ្ឋបានប្រើជាគោលក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយរបស់ខ្លួននេះ។

ប្រសិនបើសេចក្ដីសម្រេចចុងក្រោយបង្ហាញថា មានសេវាដាក់លាក់ណាមួយកន្លងមិនបាន/ក្នុងពេលនេះមិនបានផ្ដល់ដោយជនជាប់ចោទមែន, នោះទីភ្នាក់ងារនាំមុខរបស់រដ្ឋត្រូវតែ ៖

- បង្ហាញប្រាប់ថា ពិតជាមានការខកខានមិនបានផ្ដល់សេវាសមស្របជាក់លាក់ណាមួយមែន, ដែលក្នុងនោះត្រូវតែមានវិធានការកែតម្រូវ ទៅតាមសេចក្ដីត្រូវការនានារបស់កូនលោកអ្នក ដែលជាតួអង្គក្នុងបណ្ដឹងនេះ និងរបស់គ្រួសារលោកអ្នក (ដូចជាការទូទាត់សំណងជាសេវា ឬការទូទាត់សំណងប្រាក់លើថ្លៃបង់ខាតទាំងប៉ុន្មាន); និង
- ចេញវិធិការគ្រប់គ្រងសេវាអនាគតសម្រាប់ទារក និងកូនក្មេងអាយុពីរបីឆ្នាំទាំងអស់ ដែលមានពិការភាព (ជម្ងឺពិការ) និងក្រុមគ្រួសាររបស់ពួកគេ។

ទីភ្នាក់ងារនាំមុខរបស់រដ្ឋត្រូវតែចេញយន្តការ ដើម្បីអនុវត្តសេចក្ដីសម្រេចដែលខ្លួនបានដាក់ចេញនោះ ឲ្យមានប្រសិទ្ធភាព, ប្រសិនបើចាំបាច់, ដោយរួមមាននូវសកម្មភាពជំនួយបច្ចេកទេស, ការចរចា និងវិធានការកែតម្រូវ ដើម្បីធានាការប្រតិបត្តិតាម។

ប្រសិនបើទីភ្នាក់ងារនាំមុខរបស់រដ្ឋបានទទួលពាក្យបណ្ដឹងលាយលក្ខណ៍អក្សរ ដែលជាកម្មវត្ថុរបស់សវនាការត្រឹមត្រូវតាមច្បាប់, ឬមានលាយបញ្ហាវិវាទច្រើន, ដែលបញ្ហាវិវាទភាគច្រើនជាកម្មវត្ថុរបស់សវនាការនោះ, នោះទីភ្នាក់ងារនាំមុខរបស់រដ្ឋត្រូវតែទុកដាក់បញ្ហាបណ្ដឹងវិវាទពាក់ព័ន្ធសវនាការត្រឹមត្រូវតាមច្បាប់មួយអន្លើ រហូតទាល់តែដល់វេលាដែលត្រូវធ្វើសេចក្ដីសន្និដ្ឋានសវនាការ។ ក៏ប៉ុន្តែ បញ្ហាវិវាទណាក្នុងបណ្ដឹងនេះ ដែលមិនពាក់ព័ន្ធសវនាការត្រឹមត្រូវតាមច្បាប់ ត្រូវតែដោះស្រាយឲ្យទាន់ក្នុងរយៈពេល 60 ថ្ងៃប្រតិទិន និងឲ្យត្រឹមត្រូវទៅតាមនីតិវិធីនៃបណ្ដឹងរដ្ឋបាល ដែលបានពណ៌នាក្នុងឯកសារនេះ។

ពាក្យបណ្ដឹងទាំងឡាយណា ដែលបានសម្រេចជាស្ថាពរក្រោមនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ដែលពាក់ព័ន្ធភាគីដដែល។ មិនអាចលើកយកប្ដឹងម្ដងទៀតក្រោមនីតិវិធីបណ្ដឹងរដ្ឋបាលនេះទេ។ ទីភ្នាក់ងារនាំមុខរបស់រដ្ឋត្រូវតែផ្ដល់សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ភាគីដើមបណ្ដឹងឲ្យបានជ្រាបថា សេចក្ដីសម្រេចរបស់សវនាការគឺជាសេចក្ដីសម្រេច ដែលមានសុពលភាពត្រូវប្រតិបត្តតាម។

ពាក្យបណ្ដឹងចោទប្រកាន់ទីភ្នាក់ងារសាធារណៈ ឬទីភ្នាក់ងារផ្ដល់សេវាបម្រើឯកជន (រួមមានអ្នកជាប់កិច្ចសន្យាផ្ដល់សេវាអន្តរាគមន៍បឋមវ័យ ឬទីភ្នាក់ងារផ្ដល់សេវាអន្តរាគមន៍បឋមវ័យ) អំពីបទខកខានអនុវត្តតាមសេចក្ដីសម្រេចរបស់សវនាការត្រឹមត្រូវតាមច្បាប់ឥតលំអៀង ត្រូវតែដោះស្រាយដោយទីភ្នាក់ងារនាំមុខរបស់រដ្ឋ។

## ឪពុកម្ដាយស្ដីទី (Surrogate Parents)

សិទ្ធិរបស់កុមារ ដែលមានលក្ខណសម្បត្តិទទួលជំនួយក្រោមមាត្រា Part C ត្រូវបានការពារ ប្រសិនបើ ៖

- គេរកឪពុកម្ដាយរបស់កុមាររូបនោះមិនឃើញ;
- អ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យ, នៅក្រោយពេលបានព្យាយាមអស់សមត្ថភាពហើយ, មិនអាចរកឪពុកម្ដាយរបស់កុមាររូបនោះឃើញ; ឬ
- កុមាររូបនោះគឺជាបាលិត(កូនចិញ្ចឹម)របស់រដ្ឋវ៉ាស៊ីនតោនក្រោមច្បាប់របស់រដ្ឋ។

បុគ្គលិកម្នាក់ត្រូវបានចាត់តាំងឲ្យធ្វើជាឪពុកម្ដាយ "ស្ដីទី" ទៅតាមនីតិវិធីខាងក្រោមនេះ។

នីតិវិធីទាំងនេះរួមមាននូវវិធីសាស្ត្រសម្រាប់កំណត់មើល ថាតើកុមាររូបនោះត្រូវការឪពុកឬម្ដាយស្ដីទីឬទេ ហើយព្យាយាមចាត់តាំងឪពុឬម្ដាយស្ដីទីម្នាក់ ជូនកុមាររូបនោះមិនឲ្យលើសពីរយៈពេល 30 ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានកំណត់ឃើញថា កុមាររូបនោះត្រូវការឪពុកឬម្ដាយស្ដីទីមួយរូប។

លក្ខណៈវិនិច្ឆ័យខាងក្រោមត្រូវបានប្រើប្រាស់ ដើម្បីជ្រើសរើសរកមនុស្សធ្វើជាឪពុកម្ដាយស្ដីទី។ ឪពុកម្ដាយស្ដីទីត្រូវបានជ្រើសរើសដោយអ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យម្នាក់។ ហើយត្រូវតែស្របតាមលក្ខខណ្ឌតម្រូវទាំងប៉ុន្មានខាងក្រោមនេះ ៖

- គ្មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍វិជ្ជាជីវៈ ដែលនាំឲ្យមានទំនាស់ដល់ផលប្រយោជន៍របស់កុមារ ដែលគាត់ធ្វើជាតំណាងឲ្យ។
- មានចំណេះ និងជំនាញ ដែលធានាថា មានសមត្ថភាពធ្វើជាតំណាងឲ្យកុមាររូបនោះ ដោយប្រសិទ្ធភាព។
- មិនមែនជាបុគ្គលិករបស់ទីភ្នាក់ងារណាមួយរបស់រដ្ឋ; ឬជាបុគ្គលិករបស់ជនណាម្នាក់ ដែលកំពុងផ្ដល់សេវាអន្តរាគមន៍បឋមវ័យ, សេវាអប់រំ, សេវាថែទាំ, ឬសេវាដទៃៗទៀតដល់កុមាររូបនោះ ឬជាសមាជិកណាម្នាក់ក្នុងគ្រួសាររបស់កុមាររូបនោះទេ។ ជនដែលមានគុណសម្បត្តិគ្រប់គ្រាន់ធ្វើជាឪពុកឬម្ដាយស្ដីទី ក្រោមនីតិវិធីទាំងនេះ មិនជាបុគ្គលិករបស់នីតិវិធីនេះទេ ពីព្រោះគាត់បានត្រូវបង់ប្រាក់ឲ្យដោយអ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យ ដើម្បីធ្វើជាឪពុកឬម្ដាយស្ដីទី។

កាលណាកុមារម្នាក់ជាបាលិត(កូនចិញ្ចឹម)របស់រដ្ឋវ៉ាស៊ីនតោន ឬត្រូវបានដាក់ក្រោមការចិញ្ចឹមបីបាច់របស់ទីភ្នាក់ងាររបស់រដ្ឋ, នោះទីភ្នាក់ងារផ្ដល់សេវាអន្តរាគមន៍បឋមវ័យត្រូវតែពិគ្រោះយោបល់ជាមួយទីភ្នាក់ងាររបស់រដ្ឋ ដែលទទួលបន្ទុកចិញ្ចឹមកុមាររូបនោះ។

សម្រាប់កុមារដែលជាបាលិតរបស់រដ្ឋ, នោះជំនួសឲ្យការចាត់តាំងដោយទីភ្នាក់ងារផ្ដល់សេវាអន្តរាគមន៍បឋមវ័យ, ចៅក្រមដែលគ្រប់គ្រងសំណុំរឿងរបស់កុមាររូបនោះ អាចចាត់តាំងឪពុកឬម្ដាយស្ដីទី ដរាបណាជនដែលត្រូវចាត់តាំងឲ្យធ្វើជាឪពុកឬម្ដាយស្ដីទីរូបនោះ បានឆ្លងកាត់តាមលក្ខណៈវិនិច្ឆ័យខាងលើ។

ឪពុកម្ដាយចាត់តាំងមានសិទ្ធិធ្វើអ្វីគ្រប់យ៉ាងក្រោមមាត្រា Part C ដូចជាឪពុកម្ដាយបង្កើតអញ្ចឹង។

## ព័ត៌មានសម្រាប់ការទាក់ទង

ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែមស្ដីពីនីតិវិធីការពារសិទ្ធិរបស់លោកអ្នក, នោះសូមអញ្ជើញទាក់ទងអ្នកសម្របសម្រួលធនធានគ្រួសារក្នុងមូលដ្ឋានរបស់លោកអ្នក (Family Resources Coordinator, FRC) តាម ៖

**ឬ**

ប្រសិនបើលោកអ្នកមានគម្រោងដាក់ពាក្យបណ្ដឹង, ដាក់ពាក្យស្នើសុំការផ្សះផ្សា និង/ឬដាក់ពាក្យស្នើសុំសវនាការត្រឹមត្រូវតាមច្បាប់, នោះសូមអញ្ជើញទាក់ទងការិយាល័យកម្មវិធីឧបត្ថម្ភបឋមវ័យសម្រាប់ និងកូនក្មេងអាយុពីរបីឆ្នាំ (Early Support for Infants and Toddlers, ESIT) តាម ៖

Early Support for Infants and Toddlers
Department of Early Learning
PO Box 40970
Olympia, Washington 98504-0970
ទូរស័ព្ទ ៖ (360) 725-3500
ទូរសារ ៖ (360) 725-4925
គេហទំព័រ ៖ **www.del.wa.gov/esit**

**ធនធានគាំពារមាតាបិតា**
**(Parent Advocacy Resource) ៖**

Washington PAVE (Partnerships for Action, Voices for Empowerment)
6316 S. 12th St.
Tacoma, Washington 98465
ទូរស័ព្ទ ៖ 1-(800) 5-PARENT
ទូរសារ ៖ 1-(253) 566-8052
គេហទំព័រ ៖ **www.wapave.org**